# នីតិវិធីព្រហ្មទណ្ឌ នៅកម្ពុជា

CRIMINAL PROCEDURE IN CAMBODIA

នីតិវិធីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្នត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ដែលមានសរុបចំនួន ៦០៦មាត្រា។ គោលបំណងនៃក្រមនេះគឺ“កំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។”

## ហេតុអ្វីបានជាត្រូវយល់ដឹងអំពីនីតិវិធីទាំងនេះ ?

- អាចធានាសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ លើកតម្កើនសិទ្ធិរបស់ភាគីរងគ្រោះដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ
- ជៀសវាងការបំពាន និងពន្យាពេលស្វែងរកយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ
- ងាយស្រួលក្នុងការស្វែងរកជំនួយផ្នែកច្បាប់ទៅតាមដំណាក់កាលនៃនីតិវិធី

## តើបណ្តឹងធំៗមានប៉ុន្មានប្រភេទ ?

- គឺមានបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី
- បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា
- ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា និងភាគីរងគ្រោះជាម្ចាស់នៃបណ្តឹងរដ្ឋប្បវេណី
- បណ្តឹងរដ្ឋប្បវេណីអាចរលត់តាមការចចាររបស់ភាគី តែបណ្តឹងអាជ្ញាមិនអាចទេ






# តើនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជាមានដំណាក់កាលអ្វីខ្លះ ?






## ១ ដំណាក់កាលស៊ើបអង្កេត



- នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ ដែលមានភារកិច្ចធ្វើការត្រួតពិនិត្យនូវបទ ឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងតាមការបញ្ជារបស់ព្រះរាជអាជ្ញា។
- នគរបាលយុត្តិធម៌រួមមាន មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការ ពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។

**ការស៊ើបអង្កេតករណីជាក់ស្តែង:**
- ត្រូវបានបើក ក្នុងករណីមានបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ដែលជាបទល្មើសកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។

**ការស៊ើបអង្កេតបឋម:**
- ត្រូវបានបើក ក្នុងករណីមានបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមមិនជាក់ស្តែង ឬក៏ក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុត ( ៧ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស )។

## ២ ដំណាក់កាលចោទប្រកាន់



- ព្រះរាជអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ក្នុងនាមផលប្រយោជន៍សង្គម ។
- ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មុននឹងសម្រេច ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម។

ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម៖
- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

# ៣ ដំណាក់កាលស៊ើបសួរ



- ចៅក្រមស៊ើបសួរ ជាបុគ្គលសំខាន់មួយក្នុងប្រព័ន្ធតុលាការ ដែលមានតួនាទីសាកសួរស្រាវជ្រាវរកការពិតដោយដោះបន្ទុកផង និងដាក់បន្ទុកផងក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន។
- ចៅក្រមស៊ើបសួរ អាចធ្វើការបើកការស៊ើបសួរបាន លុះត្រាតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា។
- ចៅក្រមស៊ើបសួរ អាចបើកការស៊ើបសួរបុគ្គលដូចខាងក្រោម៖

- ជនត្រូវចោទ
- ដើមបណ្តឹងរដ្ឋប្បវេណី
- សាក្សី
- បុគ្គលពាក់ព័ន្ធ

- ចៅក្រមស៊ើបសួរ មានសមត្ថកិច្ចធ្វើការត្រួតពិនិត្យភស្តុតាងដូចខាងក្រោម៖

- ការឆែកឆេរ និងការចាប់យកភស្តុតាង
- កោសល្យវិច័យ
- ការត្រួតពិនិត្យបេសកកម្មអ្នកជំនាញ
- ការស្តាប់ទូរស័ព្ទ

- ការស៊ើបសួរត្រូវបានបញ្ចប់ដោយ ការលើកលែងការចោទប្រកាន់ ឬបញ្ជូនទៅការជំនុំជម្រះ។

# ៤ ដំណាក់កាលជំនុំជម្រះ



- ជាសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ ដែលចៅក្រមបើកសវនាការជំនុំជម្រះជាសាធារណៈដើម្បីស្វែងរកការពិត។
- សមត្ថកិច្ចនៃការជំនុំជម្រះកើតមាននៅពេលទទួលបណ្តឹងដោយ៖

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា

- ការជំនុំជម្រះត្រូវបានបញ្ចប់ទៅវិញនៅពេលចេញសាលក្រមលើអង្គសេចក្តី។



- បុគ្គលសំខាន់ៗក្នុងដំណាក់កាលនេះមាន៖

- ក្រឡាបញ្ជីជាអ្នកកត់ត្រានូវកំណត់ហេតុសវនាការចាប់តាំងពីពេលមុនសវនាការរហូតដល់ពេលបញ្ចប់។ ក្រឡាបញ្ជីត្រូវពិនិត្យមើលអំពីវត្តមានរបស់ភាគីពាក់ព័ន្ធនៅពេលមុនសវនាការ អានកំណត់ហេតុនានាដើម្បីឱ្យអ្នកចូលរួមសវនាការបានដឹងហេតុ និងកត់ត្រារាល់សំនួរចម្លើយនាពេលសវនាការរហូតដល់បញ្ចប់។
- មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការសម្រួលដល់នីតិវិធីតុលាការ។
- ចៅក្រមជំនុំជម្រះ។

- ចៅក្រមស៊ើបសួរនៅក្នុងនីតិវិធីដដែលមិនអាចក្លាយជាចៅក្រមជំនុំជម្រះបានទៀតនោះទេ។

# សេចក្តីសម្រេច និងការតវ៉ា



- ការសម្រេចរបស់តុលាការជាន់ទាបហៅថា សាលក្រម។
- ការប្រកាសសាលក្រមត្រូវធ្វើនៅពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយដែលកាលបរិច្ឆេទត្រូវកំណត់ដោយប្រធានសវនាការ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ដោយប្រធានសវនាការអានដោយសម្លេងខ្លាំងៗផ្នែកនៃសេចក្តីសម្រេចរបស់សាលក្រម។
- សាលក្រមដែលត្រូវប្រកាសអាចជា សាលក្រមចាត់របៀប ឬសាលក្រមលើអង្គសេចក្តី។
- សាលក្រមលើអង្គសេចក្តី៖ សាលក្រមកំបាំងមុខ សាលក្រមចាត់ទុកថាចំពោះមុខ និងសាលក្រមចំពោះមុខ។

- ភាគីពាក់ព័ន្ធអាចប្តឹងទៅតុលាការបន្តបន្ទាប់ទៀតទាក់ទងនឹងការតវ៉ា។
- បើសាលក្រមចូលជាស្ថាពរហើយ គឺមិនអាចធ្វើការតវ៉ាបានទៀតនោះទេ។

**សាលាជម្រះក្តីនៅកម្ពុជារួមមាន:**

**សាលាជម្រះក្តីជាន់ទាប**

- សាលាដំបូង

**សាលាជម្រះក្តីជាន់ខ្ពស់**

- សាលាឧទ្ធរណ៍
- តុលាការកំពូល





# ជំនួយផ្នែកច្បាប់នៅកម្ពុជា

ជំនួយផ្នែកច្បាប់ គឺជាការផ្តល់សេវាផ្នែកច្បាប់ដោយការតំណាង ឬប្រឹក្សាយោបល់ និងមិនយកប្រាក់កម្រៃ ទៅដល់ជនខ្វះខាតក្នុងការស្វែងរកយុត្តិធម៌ផ្នែកច្បាប់។



## ការស្វែងរកជំនួយផ្នែកច្បាប់អាចធ្វើឡើងតាមរយៈ:

កម្មវិធីរបស់រាជរដ្ឋាភិបាល (នៅគណៈមេធាវី និងតុលាការដំបូងរាជធានី ខេត្ត)

កម្មវិធីរបស់អង្គការក្រៅរាជរដ្ឋាភិបាល

យុត្តិធម៌គឺត្រូវតែទាដផ្តល់ឲ្យមនុស្សគ្រប់ស្រទាប់វណ្ណៈ

## ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
- CSHL, *An Overview of Legal Aid in Cambodia*, 2019


**រៀបចំដោយ:**

RAOUL WALLENBERG INSTITUTE

ស៊ុយអែត Sverige


**Material presented as a partial requirement for the completion of the Professional Legal Skills (PLS) course by the students from English Language Based Bachelor of Law (ELBBL) program of Royal University of Law and Economics (RULE).**

*It is intended as a guide only.*